# សាន់បេស ហ្គាមេន ខូអិលធីឌី

SUN BEST GARMENT CO., LTD

## កិច្ចព្រមព្រៀង

ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១ខែ

គឺចាប់ពីថ្ងៃទី.១០.....ខែមករា. ឆ្នាំ២០២៣.. ដល់ ថ្ងៃទី..០៩.. ខែកុម្ភៈ ឆ្នាំ២០២៣..

ថ្ងៃចន្ទ ៤កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោងដប់បួន មានកិច្ចប្រជុំមួយនៅ សាន់បេស ហ្គាមេន ខូអិលធីឌី មានអាសយដ្ឋានស្ថិតនៅភូមិអង្គស្នួលទី១ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានចំនួនកម្មករសរុបចំនួន១២៤១...នាក់(ស្រី១០៤៩.នាក់) មាននាយក ឈ្មោះ CHIANG CHUNG YU ជនជាតិចិន ជាក្រុមហ៊ុនកាត់ដេរសម្លៀកបំពាក់ ដែលមានលោកស្រី សុខ ចាន់ណា ជាប្រធានរដ្ឋបាលប្រចាំក្រុមហ៊ុន បានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១ខែ។

ជាកិច្ចចាប់ផ្តើមលោក CHIANG CHUNG YU ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ដល់ អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំថ្ងៃនេះ បន្ទាប់មកលោក ប្រធាន អង្គប្រជុំមានមតិសម្របសម្រួលអំពីករណី ខាងលើ និងពន្យល់ពីមូលហេតុដោយសារមិនមានការបញ្ជាទិញរបស់អតិថិជនក្នុងអំឡុងពេលនេះ។

ដូចនេះ សាន់បេស ហ្គាមេន ខូអិលធីឌី និងកម្មករនិយោជិតទាំងអស់ បានព្រមព្រៀងគ្នាដូចខាងក្រោមៈ

1-ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន១២៤១.នាក់រយៈពេល១ខែ ដោយគិតចាប់ពីថ្ងៃទី.១០....ខែ.មករា.. ឆ្នាំ២០២.៣.. រហូតដល់ថ្ងៃទី.០៩....ខែកុម្ភៈ...ឆ្នាំ២០២.៣.។

២-ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះក្រុមហ៊ុនបានព្រមព្រៀម ផ្តល់ប្រាក់ឧបត្ថម្ភជូន កម្មករនិយោជិតគឺស្មើនឹង..៧០....ដុល្លារអាមេរិក សម្រាប់កម្មករនិយោជិតម្នាក់ៗ ហើយប្រាក់ឧបត្ថម្ភនេះបើកនៅថ្ងៃទី០៩ ខែ មករា ឆ្នាំ២០២៣ ។

អង្គស្នួល ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២

សាន់ បេស ហ្គាមេន
SUN BEST GARMENT
CO., LTD.

**បានឃើញនិងឯកភាព**

**តំណាងកម្មករនិយោជិត**

**តំណាងក្រុមហ៊ុន**

សាន់ បេស ហ្គាមេន
SUN BEST GARMENT
CO., LTD.

CHZANG CHUNG YU